ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០០៧

លេខ: ១៦៨ ប្រក

# ប្រកាស

## ស្តីពី

## តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល

~~~~~~~~~~~~~~~~

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់នាយកដ្ឋានសិទ្ធអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## ស ម្រេ ច

**ប្រការ ១.-**

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ជាអង្គភាពស្ថិតនៅក្រោមឱវាទអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
~~~~~~~~~~~~~~~~

## ប្រការ ២.-

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែលមានភារកិច្ចដូចតទៅ ៖

- លើកកម្មវិធីនយោបាយស្តីពីវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលស្របតាមការវិវឌ្ឍន៍នៃប្រទេសជាតិ និងសកលលោក
- អនុវត្តទូលំទូលាយនយោបាយសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក្នុងគោលដៅជំរុញការលើកទឹកចិត្តក្នុងការការពាស្នាដៃ និងការបង្កើតផលិតផលថ្មីខាងវិស័យវប្បធម៌
- គ្រប់គ្រង សម្របសម្រួល និងធ្វើឱ្យប្រសើរនូវការអនុវត្តន៍ច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- គ្រប់គ្រង សម្របសម្រួលការងារជាមួយអង្គភាពគ្រប់គ្រងសិទ្ធិរួម
- សិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ចុះបញ្ជីការពារស្នាដៃ
- ធ្វើការទំនាក់ទំនងជាមួយអង្គភាពសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែលនៅក្រៅប្រទេស
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

## ប្រការ ៣.-

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ប្រការ ៤.-

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មានការិយាល័យចំនួន ៥ ដូចខាងក្រោម ៖

១- ការិយាល័យរដ្ឋបាល

២- ការិយាល័យការពារស្នាដៃ

៣- ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍ

៤- ការិយាល័យអប់រំ និងផ្សព្វផ្សាយ

៥- ការិយាល័យអង្គភាពគ្រប់គ្រងសិទ្ធិរួម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

អង្គការលេខរបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ៥.-

ភារកិច្ចរបស់ការិយាល័យនីមួយៗមាន៖

**១- ការិយាល័យរដ្ឋបាល ៖**

- គ្រប់គ្រងលិខិតចេញចូល
- គ្រប់គ្រងសម្ភារៈ
- គ្រប់គ្រងបុគ្គលិក
- គ្រប់គ្រងហិរញ្ញវត្ថុ
- បង្កើតគំនិតផ្តួចផ្តើមសរសេរគំរោងស្នើសុំ ដើម្បីអភិវឌ្ឍ
- ផ្តល់មតិ និងអនុសាសន៍ក្នុងការងារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ទំនាក់ទំនងស្ថាបនជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិអ្នកប្រហាក់ប្រហែល
- សម្របសម្រួលការវិវាទ
- លើកគំរោងផែនការការងារ និងទិសដៅនយោបាយរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារនាយកដ្ឋាន ។

**២- ការិយាល័យការពារស្នាដៃ ៖**

- រៀបចំសំណុំបែបបទសុំសិទ្ធិគ្រប់គ្រងស្នាដៃ ចុះបញ្ជីការពារស្នាដៃអ្នកនិពន្ធ និងសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍
- ទទួលសំណុំបែបបទសុំសិទ្ធិគ្រប់គ្រងស្នាដៃ ចុះបញ្ជីការពារស្នាដៃអ្នកនិពន្ធ និងសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតកសាសន៍
- រៀបចំលិខិតអនុញ្ញាតសុំសិទ្ធិគ្រប់គ្រងស្នាដៃបណ្តោះអាសន្ន លិខិតបញ្ជាក់ការចុះបញ្ជីការពារស្នាដៃ និងវិញ្ញាបនបត្រចុះបញ្ជីស្នាដៃអ្នកនិពន្ធ និងលិខិតអនុញ្ញាតសុំសិទ្ធិធ្វើអាជីវកម្មលើស្នាដៃគ្មានមរតក-សាសន៍
- តំកល់ឯកសារស្នាដៃអ្នកនិពន្ធ ស្នាដៃអ្នកសម្តែង ផលិតករហ្វូណូក្រាម និងរៀបចំប្រវត្តិរូបស្នាដៃអ្នកនិពន្ធ
- រៀបចំផែនការដើម្បីអភិវឌ្ឍការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ អន្តរជាតិលើការការពារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ផ្តល់ពត៌មាន និងផ្តល់ការពិគ្រោះយោបល់ជាមួយអតិថិជន
- លើកគម្រោងផែនការការងារ និងយុទ្ធសាស្ត្រក្នុងការការពារស្នាដៃ
- ធ្វើរបាយការណ៍សកម្មភាពការងារ ។

៣- ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍ ៖

- សិក្សាស្រាវជ្រាវពីស្ថានភាពរបស់អ្នកនិពន្ធ
- សិក្សាស្រាវជ្រាវពីប្រភេទស្នាដៃ
- សិក្សាស្រាវជ្រាវពីការការពារស្នាដៃនៅបណ្ដាប្រទេសផ្សេងៗ
- សិក្សាស្រាវជ្រាវពីច្បាប់ បទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងអង្គភាពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលអន្តរជាតិ
- សិក្សាស្រាវជ្រាវនូវផលិតផលវប្បធម៌បង្កើតថ្មីដែលទាក់ទងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- សិក្សាស្រាវជ្រាវ និងតាមដានរាល់សកម្មភាពរំលោភសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ជំរុញឱ្យមានការបង្កើតថ្មីនូវផលិតផលខាងវិស័យវប្បធម៌
- រៀបចំចងក្រងឯកសារសម្រាប់ទិសដៅការអនុវត្តសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- រៀបចំធ្វើសេចក្ដីព្រាងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗក្នុងនាយកដ្ឋាន
- បង្កើតគំនិតផ្ដួចផ្ដើមសរសេរគំរោងស្នើសុំ ដើម្បីអភិវឌ្ឍ
- លើកគំរោងផែនការការងារ និងទិសដៅអភិវឌ្ឍន៍គោលនយោបាយរបស់នាយកដ្ឋាន
- សរុបរបាយការណ៍ និងលើកគោលការដើម្បីអភិវឌ្ឍសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ធ្វើរបាយការណ៍សកម្មភាពការងារ ។

៤-ការិយាល័យអប់រំ និងផ្សព្វផ្សាយ ៖

- រៀបចំការផ្សព្វផ្សាយច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិទាក់ទងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល តាមគ្រប់មធ្យោបាយ
- បង្កើតវគ្គបណ្ដុះបណ្ដាលសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- ចងក្រងឯកសារ បោះពុម្ពឯកសារ និងព្រឹត្តិបត្រសិទ្ធិអ្នកនិពន្ធ
- រៀបចំសរសេរអត្ថបទនានា ដែលពាក់ព័ន្ធនិងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលបញ្ចូលក្នុងគេហ៍ទំព័រ
- រៀបចំចងក្រងឯកសារជំនួយស្មារតីនៃសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បោះពុម្ពសៀវភៅ ឬគំនូរផ្សាយ ឬបង្កើតជាស្ពុតខ្លីៗអប់រំពីការការពាសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- សរុបរបាយការណ៍ និងលើកគោលការណ៍ដើម្បីអភិវឌ្ឍសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បង្កើតគំនិតផ្ដួចផ្ដើមសរសេរគំរោងស្នើសុំ ដើម្បីអភិវឌ្ឍ
- លើកគំរោងផែនការការងារសម្រាប់ការអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍សកម្មភាពការងារ ។

៥- ការិយាល័យអង្គភាពគ្រប់គ្រងសិទ្ធិរួម ÷

- ជំរុញបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម
- ពិនិត្យតាមដានណែនាំអង្គភាពគ្រប់គ្រងសិទ្ធិរួម
- ទំនាក់ទំនងជាមួយអង្គភាពគ្រប់គ្រងសិទ្ធិរួមនៅបរទេស
- រៀបចំបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងអង្គភាពគ្រប់គ្រងសិទ្ធិរួម
- បង្កើតគំនិតផ្តួចផ្តើមសរសេរគំរោងស្នើសុំ ដើម្បីអភិវឌ្ឍ
- លើកគំរោងផែនការការងារជាយុទ្ធសាស្ត្រតាមដានការអនុវត្តនៃអង្គភាពគ្រប់គ្រងសិទ្ធិរួម
- ផ្តល់ពត៌មាន និងផ្តល់ការពិគ្រោះយោបល់ជាមួយអង្គភាព ឬក្រុមហ៊ុនពាក់ព័ន្ធ
- ធ្វើរបាយការណ៍សកម្មភាពការងារ ។

**ប្រការ ៦.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង និងអង្គភាពពាក់ពន្ធ័ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ហ៊ឹម ឆែម**

*ចំលងជូន*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ
- រដ្ឋលេខាធិការមុខងារសាធារណៈ

(ដើម្បីជូនជ្រាបជាពត៌មាន)

- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៧៦៨. ប្រក.ទវស.បុ ចុះថ្ងៃទី ១៦... ខែ សីហា ឆ្នាំ២០០៧

# អង្គការលេខ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល

